# អត្ថបទស្រាវជ្រាវ
# ស្ថានភាពដៃគូអភិវឌ្ឍនៅកម្ពុជា
# ឆ្នាំ២០១១

ដោយ

**ឯកឧត្តម ឌិន វីរៈ**
សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឋានៈស្មើ រដ្ឋលេខាធិការ)
អ៊ីមែល៖ dinvirak@ecosocc.gov.kh

# ស្ថានភាពដៃគូអភិវឌ្ឍនៅកម្ពុជា

ឆ្នាំ២០១១

ដោយ ឯកឧត្តម **ឱន ធីរៈ**

សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សន្និទានកម្ម

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការកិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ និងភាពជាដៃគូពីវិស័យឯកជន ដែលរួមមាន វិនិយោគផ្ទាល់ពីបរទេស។ កម្ពុជាទទួលបានការអភិវឌ្ឍនិងរីកចម្រើនដោយមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនិងកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍផងដែរ។

បច្ចុប្បន្ន ស្ថានភាពជំនួយពីដៃគូអភិវឌ្ឍមានការប្រែប្រួល ដោយសារប្រទេសដៃគូអភិវឌ្ឍមួយចំនួន បានផ្លាស់ប្តូរអាទិភាពជំនួយទៅកាន់ប្រទេសដែលមានតម្រូវការនិងភាពចាំបាច់ខ្ពស់ជាង និងឥទ្ធិពលនៃវិបត្តិផ្សេងៗ ជាអាទិ៍ ប្រទេសខ្លះបានរក្សាកម្រិតជំនួយមកកាន់កម្ពុជានៅដដែល ប្រទេសខ្លះបានបន្ថយជំនួយអភិវឌ្ឍមកកាន់កម្ពុជា រីឯប្រទេសខ្លះទៀតបាននិងកំពុងបង្កើនជំនួយអភិវឌ្ឍមកកាន់កម្ពុជា រួមមានប្រទេសចិន។

ដើម្បីចូលរួមក្នុងការអនុវត្ត យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល (ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព)ឲ្យបានជោគជ័យ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំការសិក្សាស្រាវជ្រាវមួយ ដើម្បីវិភាគស្ថានភាពដៃគូអភិវឌ្ឍនៅកម្ពុជា។

## គោលបំណងនៃការសិក្សា

គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺស្វែងយល់ពីស្ថានភាព និងនិន្នាការរបស់ដៃគូអភិវឌ្ឍនៅកម្ពុជា និងផ្តល់ព័ត៌មាននិងអនុសាសន៍សម្រាប់អ្នកធ្វើគោលនយោបាយ។

## វិធីសាស្ត្រនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះ ផ្អែកលើទិន្នន័យនិងព័ត៌មានដែលមានស្រាប់ (រួមមាន របាយការណ៍ និងឯកសារផ្សេងៗ) និងការសម្ភាសជាមួយមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ ដៃគូអភិវឌ្ឍទ្វេភាគីនិងពហុភាគី និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

ការសិក្សានេះ ពិនិត្យលើស្ថានភាពនិងនិន្នាការដៃគូអភិវឌ្ឍនៅកម្ពុជាសម្រាប់រយៈពេលខ្លីនិងមធ្យម។

## ស្ថានភាពអភិវឌ្ឍន៍ទូទៅ

រាជរដ្ឋាភិបាល បាននិងកំពុងខិតខំប្រឹងប្រែងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយទទួលបានលទ្ធផលវិជ្ជមាន គឺកាត់បន្ថយភាពក្រីក្រនៅកម្ពុជាបានប្រមាណជាង ១ភាគរយក្នុងមួយឆ្នាំ។

កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពីសំណាក់ដៃគូនានា រួមមាន

- *ស្ថាប័នទ្វេភាគី* ជាអាទិ៍ ចិន អូស្ត្រាលី (AUSAID) ជប៉ុន (JICA) សហរដ្ឋអាមេរិក (USAID) ចក្រភពអង់គ្លេស (DFID) ដាណឺម៉ាក (DANIDA) កាណាដា (CIDA) សាធារណរដ្ឋកូរ៉េ (KOICA)។
- *ស្ថាប័នពហុភាគី* រួមមាន ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងសហភាពអឺរ៉ុប។

កម្ពុជាមានបំណុលប្រមាណពាក់កណ្តាលពីដៃគូអភិវឌ្ឍពហុភាគី ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី(២៨%) និងធនាគារពិភពលោក (១៧%)។ សម្រាប់ឆ្នាំ២០១១-២០១៣ កម្ពុជាបានបង្កើនកម្ចីពីដៃគូអភិវឌ្ឍទ្វេភាគី ក្នុងចំណោមនោះ ចិនបានក្លាយជាដៃគូទ្វេភាគីសំខាន់ជាងគេ ដែលរួមមានកម្ចីប្រមាណ ៥៨ភាគរយនៃកម្ចីទ្វេភាគី។

## ការវិភាគនិន្នាការ

ធនាគារពិភពលោក បានចាត់ថ្នាក់ប្រទេសឬសេដ្ឋកិច្ចទៅតាមចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ (Gross National Income, GNI per capita) ដូចតទៅ៖

- ចំណូលទាប (Low Income)៖ តិចជាង ១ ០០៥ ដុល្លារអាមេរិក
- ចំណូលមធ្យមកម្រិតទាប (Lower Middle Income)៖ ពី១ ០០៦ ដល់៣ ៩៧៥ ដុល្លារ
- ចំណូលមធ្យមកម្រិតខ្ពស់ (Upper Middle Income)៖ ពី៣ ៩៧៦ ដល់១២ ២៧៥ ដុល្លារ
- ចំណូលខ្ពស់ (High Income)៖ ចាប់ពី១២ ២៧៦ដុល្លារ

យោងតាមចំណាត់ថ្នាក់នេះ ព្រះរាជាណាចក្រកម្ពុជា កំពុងឈានឡើងដល់កម្រិតចំណូលមធ្យមថ្នាក់ក្រោម។ កំណើនផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់នៅកម្ពុជា បានកើនឡើងដល់ ៨៣០ដុល្លារនៅឆ្នាំ២០១០[1]។ មានន័យថា កម្ពុជាលែងមានឱកាសទទួលបាននូវឥណទានសម្បទានដូចបណ្តាឆ្នាំកន្លងមក។ នេះគឺជាកត្តាមួយក្នុងចំណោមកត្តាដទៃទៀតដែលអាចនាំឲ្យជំនួយអភិវឌ្ឍន៍

[1] ទិន្នន័យនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

ផ្លូវការ (Official Development Assistance - ODA) សម្រាប់កម្ពុជា មានការថយចុះ ទន្ទឹមគ្នានឹងកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

អ្នកសេដ្ឋកិច្ចខ្លះបានសម្តែងការបារម្ភថា កម្ពុជាអាចធ្លាក់ចូលក្នុង«*អន្ទាក់ចំណូលមធ្យម*» (The Middle Income Trap) យោងតាមបទពិសោធនៃបណ្តាប្រទេសដែលបានឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍នេះ។ មានន័យថានៅក្នុងដំណាក់កាលដែលមានចំណូលទាប (គឺតិចជាង ១០០៥ ដុល្លារ) ប្រទេសកំពុងអភិវឌ្ឍន៍ទទួលបាននូវជំនួយអភិវឌ្ឍន៍ផ្លូវការ រួមមានឥណទានសម្បទាន(Concessional Loans)និងជំនួយឥតសំណង(Grants)សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឲ្យមានការរីកចម្រើនរហូតដល់ដំណាក់កាលចំណូលមធ្យមដែលប្រទេសទាំងនោះមានលទ្ធភាពប្រឹងប្រឹងអភិវឌ្ឍដោយខ្លួនឯង។

*ការប្រើហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ* (Development Partner Disbursements)




ប្រភព៖ CDC

កត្តាមួយទៀតដែលឆ្លុះបញ្ចាំងអំពីនិន្នាការថយចុះនៃជំនួយអភិវឌ្ឍន៍នៅកម្ពុជា ដូចបង្ហាញលើក្រាភិចខាងលើនេះ គឺឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចនៅបណ្តាប្រទេសលើពិភពលោក ហើយម្យ៉ាងទៀត ដៃគូអភិវឌ្ឍមួយចំនួន បានបង្វែរអាទិភាពទៅកាន់ប្រទេសផ្សេងដែលមានតម្រូវការជំនួយអភិវឌ្ឍន៍បន្ទាន់ជាង។

អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោកបានរួមគ្នារៀបចំធ្វើការវិភាគនិរន្តរភាពបំណុល ដោយមានកិច្ចសហការពីធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ តារាង១ ខាងក្រោមនេះបង្ហាញថា កម្ពុជាមានហានិភ័យបំណុលកម្រិតមធ្យម[2]។

[2] Cambodia’s Debt Sustainability Analysis indicates that the risk of debt distress is moderate.

| *តារាង១៖ សូចនាករបំណុលសាធារណៈក្រៅប្រទេស*<br>(Cambodia: External Public Debt Indicators) | | | | | | |
|---|---|---|---|---|---|---|
| | Indicative Thresholds | 2005 | 2006 | 2007 | 2008 | 2009 |
| តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុល[3] គិតជាភាគរយនៃ (NPV of debt, as a percent of): | | | | | | |
| ផសស(GDP) | 30 | 24.2 | 23.1 | 23 | 19.8 | 22 |
| ការនាំចេញ(Exports) | 100 | 40 | 32.9 | 35 | 36.7 | 41 |
| ចំណូលរដ្ឋ (Government Revenue) | 200 | 210.2 | 176 | 191 | 164.9 | 189 |
| សេវាបំណុល4 គិតជាភាគរយនៃ<br>Debt service, as a percent of: | | | | | | |
| ការនាំចេញ(Exports) | 15 | 0.9 | 0.9 | 1 | 0.9 | 1 |
| ចំណូលរដ្ឋ (Government Revenue) | 25 | 4.2 | 3.7 | 4 | 4.2 | 5 |
| Source: WB/IMF Debt Sustainability Analysis 2003-2010 and IMF Country Reports 2004-2011. | | | | | | |

មកដល់ឆ្នាំ២០០៨ អនុបាតបំណុលបានថយចុះ (Decline in Debt Ratios) ដល់១៩,៨ភាគរយនៃផលិតផលក្នុងស្រុកសរុប ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់និងលក្ខខណ្ឌល្អប្រសើរ។ ប៉ុន្តែ ចាប់ពីឆ្នាំ២០០៩ អនុបាតបំណុលបានកើនឡើង មួយផ្នែកគឺដោយសារការកើនឡើងនៃជំនួយបរទេសពីដៃគូអភិវឌ្ឍដែលមានស្រាប់និងដៃគូថ្មីដើម្បីប្រឈមនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក។ នៅដំណាច់ឆ្នាំ២០០៩ កម្ពុជាមានបំណុលបរទេសប្រមាណ ២២ភាគរយនៃផលិតផលក្នុងស្រុកសរុប (ផសស) ដែលមានកម្រិតទាបជាងចំណុចកំណត់គឺ ៣០ភាគរយ។

ការវិភាគបង្ហាញថា ជំនួយអភិវឌ្ឍន៍សម្រាប់កម្ពុជា អាចនឹងកើនឡើងក្នុងរយៈពេលខ្លី ដោយសារកម្រិតហានិភ័យបំណុលមធ្យម ហើយឥណទានសម្បទានទំនងជាថយចុះក្នុងរយៈពេលមធ្យមនិងវែង ដោយសារកម្ពុជានឹងឈានចូលក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មី។

[3] តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុល គឺជាតម្លៃអប្បហារនៃរាល់សេវាបំណុលក្នុងពេលណាមួយ។ (NPV of debt is defined as the discounted value of all future debt-service payments due on the debt disbursed and outstanding at a given point in time.)

[4] សេវាបំណុលសំដៅដល់ការប្រាក់និងការរំលស់ប្រាក់ដើមនៃបំណុលរយៈពេលមធ្យមនិងវែង។ (Debt service is defined as the sum of interest and amortization of medium and long-term debt.)

## អនុសាសន៍គោលនយោបាយជាតិ

<u>ជម្រើសគោលនយោបាយរយៈពេលខ្លីនិងមធ្យម៖</u>

- ពិពិធកម្មប្រភពជំនួយអភិវឌ្ឍ (ដៃគូទ្វេភាគីនិងដៃគូពហុភាគី)
- អភិវឌ្ឍន៍ថវិកាជាតិ (បង្កើនមូលដ្ឋានពន្ធ ដូចជាពន្ធលើអចលនទ្រព្យ)

<u>ជម្រើសគោលនយោបាយរយៈពេលមធ្យមនិងវែង៖</u>

- ឆ្ពោះទៅរកស្វ័យភាពថវិកា (ពង្រីកមូលដ្ឋានពន្ធ ដូចជាពន្ធលើប្រាក់ចំណូលបុគ្គល)
- ជម្រើសអភិវឌ្ឍន៍ផ្សេងទៀត (ការអភិវឌ្ឍវិនិយោគឯកជន)

នៅក្នុងរយៈពេលវែង តួនាទីនៃវិនិយោគឯកជន (វិនិយោគបរទេសនិងវិនិយោគក្នុងស្រុក) នឹងមាននិន្នាការកើនឡើងជំនួសឲ្យតួនាទីនៃជំនួយអភិវឌ្ឍន៍ផ្លូវការ។ ដូចនេះ ការធ្វើឲ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគ គឺជាកត្តាចាំបាច់។

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមអ្នកដែលបានផ្តល់ព័ត៌មាន

| *ល.រ* | *ឈ្មោះ* | *តួនាទី* | *អង្គភាព* |
|---|---|---|---|
| 1. | ទូន ថាវរៈ | អគ្គនាយក | អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ |
| 2. | Rith Vuthy | អគ្គលេខាធិការរង | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| 3. | ជា ហួត | អ្នកសេដ្ឋកិច្ច | ធនាគារពិភពលោក |
| 4. | ស្រី ចន្ទី | កុងស៊ុលតង់ | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា |

## ប្រភពទិន្នន័យនិងឯកសារយោង

ប្រភពចម្បងនៃទិន្នន័យនិងឯកសារនានា រួមមាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នផ្សេងទៀត។


1. Asian Development Bank's Country Partnership Strategy: Cambodia 2011-2013.
2. Cambodia Evaluation of Aid Effectiveness November 2008, by Independent Review Team.
3. Cambodia ODA Database: http://cdc.khmer.biz accessed on 29 August 2011.
4. Evaluation of DFID Country Programmes: Cambodia, May 2009.
5. International Monetary Fund, "Debt Sustainability in Low-Income Countries – Towards a Forward-Looking Strategy", 2003.
6. Cambodia: Joint IMF-World Bank Debt Sustainability Analysis (DSA), 2010.
7. Cambodia: Joint IMF-World Bank Debt Sustainability Analysis (DSA), 2009.
8. Cambodia: Joint IMF-World Bank Debt Sustainability Analysis (DSA), 2008.
9. The Cambodia Aid Effectiveness Report, CRDB/CDC, 2010.
10. Seligson Mitchell A., and Passé-Smith John T, "Development and Under-Development", 2nd ed., Lynne Rienner Publishers, 1998.
11. World Bank East Asia and Pacific Economic Update 2011.
12. International Monetary Fund World Economic Outlook 2011.
13. IMF Country Reports 2004-2011.
14. Van Den Berg Hendrik, "Economic Growth and Development", McGraw-Hill, 2001.